ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន
- បានឃើញអនុក្រឹត្យលេខ១៩៩ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្ដីពីបែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៧

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្ដល់តាវកាលិកសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន លើកលែងតែអតីតយោធិនដែលមានឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវី ដែលត្រូវអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ១៩៩ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្ដីពីបែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។

**មាត្រា២ .-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សំដៅដល់ការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ
- គ្រោះថ្នាក់ការងារ សំដៅដល់គ្រោះថ្នាក់ចំពោះរូបកាយមន្ត្រីសាធារណៈ ដោយធ្វើការ ឬក្នុងពេលធ្វើការជូនក្រសួង ស្ថាប័ន អង្គភាពរបស់ខ្លួន

- គ្រោះថ្នាក់ពេលធ្វើដំណើរ សំដៅដល់គ្រោះថ្នាក់ចំពោះរូបកាយមន្ត្រីសាធារណៈក្នុងពេលធ្វើដំណើរពីលំនៅឋានត្រង់ឆ្ពោះទៅកន្លែងធ្វើការឬវិលមកវិញដោយគ្មានឈប់ ឬវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ក្រៅពីការងារដែលក្រសួង ស្ថាប័ន ឬអង្គភាពតម្រូវឱ្យទៅ
- ជំងឺវិជ្ជាជីវៈ សំដៅដល់ជំងឺនានាដែលកើតឡើងដោយមានមូលហេតុពីការងារឬពាក់ព័ន្ធនឹងការងារ ទោះជាជំងឺនោះកើតឡើងក្នុងកំលុងពេលបំពេញការងារឬក្នុងពេលណាមួយក្រោយបំពេញការងារក៏ដោយ
- របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គមដែលត្រូវផ្តល់ការគាំពារចំពោះគ្រោះថ្នាក់ ឬជំងឺ ឬបញ្ហាសុខភាពដែលមិនពាក់ព័ន្ធនឹងហានិភ័យការងារ
- តាវកាលិកផ្នែកហានិភ័យការងារ សំដៅដល់ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ វិភាជន៍ ឬធនលាភបាត់បង់សមត្ថភាពការងារសម្រាប់ផ្តល់ជូនមន្ត្រីសាធារណៈដែលរងគ្រោះដោយគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ និងធនលាភឧត្តរជីវី សម្រាប់ផ្តល់ជូនសិទ្ធិវន្តនៃជនរងគ្រោះ ដែលរងគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ បណ្តាលឱ្យបាត់បង់ជីវិត
- ក្មេងកំព្រា សំដៅដល់ក្មេងកំព្រាដែលគ្មានឪពុកម្តាយនិងរស់នៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះដោយហានិភ័យការងារ
- តាវកាលិកផ្នែកថែទាំសុខភាព សំដៅដល់សេវាបង្ការសុខភាពនិងសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ
- សេវាបង្ការសុខភាព សំដៅដល់សកម្មភាពនានាដូចជា ការស្រាវជ្រាវរកជំងឺឬការកំណត់ជាមុននូវសញ្ញាណហានិភ័យផ្នែកសុខភាព ការអប់រំសុខភាព ការផ្តល់ប្រឹក្សា កម្មវិធីចាក់ថ្នាំបង្ការ ឬអន្តរាគមន៍នានា ដើម្បីបង្ការកុំឲ្យមានបញ្ហាផ្នែកសុខភាព
- បច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ សំដៅដល់បច្ចេកទេសឬវិធីសាស្ត្រនៃការធ្វើរោគវិនិច្ឆ័យ ការព្យាបាលនិងថែទាំត្រឹមត្រូវតាមក្បួនវេជ្ជសាស្ត្រ ដែលធ្វើឡើងដោយអ្នកមានវិជ្ជាជីវៈ ទទួលស្គាល់ដោយគណៈវិជ្ជាជីវៈសុខាភិបាល និងត្រូវបានអនុញ្ញាតច្បាប់ឲ្យប្រកបមុខរបរតាមវិជ្ជាជីវៈដោយក្រសួងសុខាភិបាល
- សល្យសាស្ត្រ សំដៅដល់ការវះកាត់តាមរបៀបវេជ្ជសាស្ត្រក្នុងបំណងព្យាបាល
- មូលដ្ឋានសុខាភិបាល សំដៅដល់អង្គភាពសុខាភិបាលសាធារណៈឬឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល
- សេវាពិគ្រោះជំងឺក្រៅ សំដៅដល់សេវាពិនិត្យនិងពិគ្រោះជំងឺ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ

- សេវាសង្គ្រោះបន្ទាន់ សំដៅដល់អន្តរាគមន៍ទាំងឡាយដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក និងត្រូវធ្វើជាបន្ទាន់ក្នុងគោលបំណងសង្គ្រោះជីវិត ឬជួយការពារការបាត់បង់អវយវៈ ឬសរីរាង្គណាមួយរបស់ជនរងគ្រោះឬអ្នកជំងឺ
- ថ្លៃតាមសេវា សំដៅដល់ថ្លៃសេវាព្យាបាលនីមួយៗរបស់មូលដ្ឋានសុខាភិបាល
- វិភាជន៍ សំដៅដល់ប្រាក់ឧបត្ថម្ភដែលត្រូវផ្តល់ជូនជនរងគ្រោះតែម្តងគត់
- ធនលាភ សំដៅដល់ប្រាក់ឧបត្ថម្ភដែលត្រូវផ្តល់ជូនជនរងគ្រោះដោយហានិភ័យការងារជាកាលិក
- ធនលាភឧត្តរជីវី សំដៅដល់ប្រាក់ឧបត្ថម្ភដែលបានផ្តល់ឲ្យប្តី ប្រពន្ធ ឬកូននៅក្នុងបន្ទុក...។

## ជំពូកទី២

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារ

### ផ្នែកទី១

### គោលការណ៍រួម

**មាត្រា៣ .-**

មន្ត្រីសាធារណៈដូចមានចែងក្នុងមាត្រា៣នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារនៅពេលទទួលរងហានិភ័យការងារ។

ជនរងគ្រោះដោយហានិភ័យការងារឬសិទ្ធិវន្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅបេឡាជាតិរបបសន្តិសុខសង្គម(**ប.ស.ស.**) និងក្រសួង ស្ថាប័ន ឬអង្គភាពសាមី អំពីគ្រោះថ្នាក់ដែលបានកើតឡើងចំពោះខ្លួន លើកលែងតែករណីប្រធានសក្តិ ឬការមិនមានលទ្ធភាព ឬមានមូលហេតុសមស្រប។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ឬអង្គភាពសាមី ត្រូវជូនដំណឹងតាមគ្រប់មធ្យោបាយ មកបេឡាជាតិរបបសន្តិសុខសង្គម(**ប.ស.ស.**)ពីឧបទ្ទវហេតុនៃហានិភ័យការងារយ៉ាងយូរ៤៨(សែសិបប្រាំបី)ម៉ោងនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានការស្នើសុំព័ត៌មានពីប.ស.ស.។ សេចក្តីសន្និដ្ឋាននៃហានិភ័យការងារ ត្រូវបានកំណត់ដោយអនុលោមតាមលទ្ធផលនៃការអង្កេតហានិភ័យការងារដែលធ្វើឡើងដោយ **ប.ស.ស.**។

### ផ្នែកទី២

### ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

**មាត្រា៤ .-**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារ រួមមាន៖

- ការព្យាបាលនិងថែទាំមុខរបួសឬជំងឺដែលបណ្តាលមកពីហានិភ័យការងារតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ ទោះដោយសម្រាកឬមិនសម្រាកនៅក្នុងមន្ទីរពេទ្យក្តី រហូតដល់ជាសះស្បើយ

- ការផ្តល់សេវាសង្គ្រោះបន្ទាន់
- ការផ្គត់ផ្គង់ឱសថសម្រាប់ការព្យាបាលនិងសម្ភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល
- ការផ្តល់សេវាស្តារនីតិសម្បទា មានជាអាទិ៍ ការផ្គត់ផ្គង់ ការថែទាំ ឬការជួសជុលឧបករណ៍អវយវៈ ឬសរីរាង្គសិប្បនិម្មិត ឬការកែទម្រង់រាងកាយដែលតម្រូវដោយគ្រូពេទ្យផ្លូវការ ការសម្របសម្រួលមុខងារ ឬការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈឡើងវិញ
- ការផ្តល់សេវាដឹកសពឬបញ្ជូនជនរងគ្រោះពេលសង្គ្រោះបន្ទាន់។

## ផ្នែកទី៣
## ការផ្តល់វិភាជន៍និងធនលាភ
## សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

**មាត្រា៥ .-**

ក- មន្ត្រីសាធារណៈដែលរងគ្រោះដោយហានិភ័យការងារបណ្តាលឲ្យមានការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង២០%(ម្ភៃភាគរយ) មានសិទ្ធិទទួលបានវិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ ដែលត្រូវបើកផ្តល់ជូនតែម្តងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម៖

**វ.ប.ក. = ប.ថ. x ក.ប.ក. x ២០%ម.ត.ប. ដែល៖**

- **វ.ប.ក.** គឺជាវិភាជន៍បាត់បង់សមត្ថភាពការងារ
- **ប.ថ.** គឺជាប្រាក់បៀវត្សប្រចាំថ្ងៃរបស់ជនរងគ្រោះ ដែលស្មើនឹងបៀវត្សមូលដ្ឋានប្រចាំខែរបស់ជនរងគ្រោះចែកនឹង២២ថ្ងៃ
- **ក.ប.ក.** គឺជាកម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍របស់ជនរងគ្រោះ
- **ម.ត.ប.** គឺជាមេគុណតម្លៃបច្ចុប្បន្នគិតតាមអាយុរបស់ជនរងគ្រោះ។

ខ- មន្ត្រីសាធារណៈ ដែលរងគ្រោះដោយហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី២០%(ម្ភៃភាគរយ)ឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ដែលត្រូវគិតតាមរូបមន្តដូចខាងក្រោម៖

**ធ.ល. = ប.ខ. x ៤/៥ក.ប.ក.** ដែល៖

- **ធ.ល.** គឺជាធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍
- **ប.ខ.** គឺជាប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់ជនរងគ្រោះ

ការផ្តល់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្តោះអាសន្នជានិច្ច។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឲ្យមានការពិនិត្យសុខភាពនិងសមត្ថភាពការងារឡើងវិញក្នុងរយៈពេល១២(ដប់ពីរ)ខែយ៉ាងយូរ។ សាមីជនដែលទទួល

បានធនលាភនេះ ត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាពនិងសមត្ថភាពការងារ តាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម។

ក្នុងករណីដែលមានតាវកាលិកត្រួតគ្នារវាងធនលាភនិងប្រាក់សោធន សាមីជនមានសិទ្ធិទទួលបានតែតាវកាលិកណាមួយដែលមានចំនួនទឹកប្រាក់ខ្ពស់ជាងប៉ុណ្ណោះ។

កម្រិតនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវកំណត់នៅក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ។

គណៈកម្មការវេជ្ជសាស្ត្រនៃ**ប.ស.ស.** ឬគ្រូពេទ្យផ្លូវការដែលទទួលស្គាល់ដោយ**ប.ស.ស.** ត្រូវកំណត់កម្រិតនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ក្នុងករណីដែលកម្រិតនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍មិនមានចែងនៅក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ។

មេគុណតម្លៃបច្ចុប្បន្ន ត្រូវកំណត់នៅក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ការកែប្រែមេគុណតម្លៃបច្ចុប្បន្ន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៤
## ការផ្តល់វិភាជន៍បូជាសពនិងធនលាភឧត្តរជីវី

**មាត្រា៦ .-**

ក្នុងករណីដែលមានហានិភ័យការងាររហូតដល់បាត់បង់ជីវិត អ្នកដែលមានករណីយកិច្ចចាត់ចែងបូជាសពជនរងគ្រោះ ត្រូវទទួលបានវិភាជន៍បូជាសពចំនួន១០(ដប់)លានរៀល។ វិភាជន៍នេះ ត្រូវតែផ្តល់ជូនទៅជនដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ។

វិភាជន៍បូជាសពនេះ អាចកែសម្រួលឡើងវិញដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧ .-**

ក្នុងករណីដែលមានហានិភ័យការងាររហូតដល់បាត់បង់ជីវិត សិទ្ធិវន្តនៃជនរងគ្រោះមានសិទ្ធិទទួលបានធនលាភឧត្តរជីវី។

សិទ្ធិវន្តនៃជនរងគ្រោះ ដោយហានិភ័យការងាររហូតបាត់បង់ជីវិត រួមមាន៖

ក- ប្តីឬប្រពន្ធរបស់សាមីជនរងគ្រោះ ដែលមានសំបុត្រអាពាហ៍ពិពាហ៍មុនពេលមានហានិភ័យការងារ ឬមុនពេលទទួលមរណភាពដោយហានិភ័យការងារនៃប្តីឬប្រពន្ធ

ខ- កូនដែលមានអាយុត្រឹម១៨(ដប់ប្រាំបី)ឆ្នាំចុះ ដែលមិនទាន់មានគូស្រករនិងមានស្ថានភាពដូចខាងក្រោម៖

- ជាកូនបង្កើត

- ក្នុងករណីមានការលែងលះឬករណីមរណភាពនៃប្តីឬប្រពន្ធ កូននៃគូស្រករក្រោយ ដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ ក៏មានសិទ្ធិដូចកូននៃអាពាហ៍ពិពាហ៍ទីមួយដែរ។
- កូនសុំរបស់សាមីជនរងគ្រោះ ដែលបានសុំស្របតាមបទប្បញ្ញត្តិជាធរមាន ឬក្មេងកំព្រារស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ។

អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់២១(ម្ភៃមួយ)ឆ្នាំចុះ ចំពោះកូនដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬកូនដែលកំពុងរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈឬឯកជនដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ព្រមទាំងមានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ។

ចំពោះកូនពិការឬមានជំងឺរ៉ាំរ៉ៃ ដែលមិនមានលទ្ធភាពធ្វើការងារមានប្រាក់ឈ្នួល មិនមានការកំណត់អាយុទេ។

គ- ឪពុកម្តាយឬមនុស្សចាស់ដែលមានអាយុយ៉ាងតិច៥៥(ហាសិបប្រាំ)ឆ្នាំ មិនមានប្រកបមុខរបរមានប្រាក់ចំណូល និងត្រូវនៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ។

**មាត្រា៨** .-

ធនលាភឧត្តរជីវី ត្រូវបានផ្តល់ជូនប្រចាំខែតាមរូបមន្តដូចខាងក្រោម៖

ក- ចំពោះសិទ្ធិវន្ត ជារូមមានប្តីឬប្រពន្ធ កូន និងឪពុកម្តាយ ឬមនុស្សចាស់នៅក្នុងបន្ទុក៖

- ប្តីឬប្រពន្ធ = ៣/៥ x ៦៣%**ប.ខ.** ដែល**ប.ខ.**ជាបៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៦៣%ប.ខ.
- ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុក = ៧%ប.ខ.

ខ- ចំពោះសិទ្ធិវន្តជារូមមាន ប្តីឬប្រពន្ធ និងកូន៖

- ប្តីឬប្រពន្ធ = ៣/៥ x ៧០%ប.ខ.
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០%ប.ខ.

គ- ចំពោះសិទ្ធិវន្ត ជារូមមានប្តីឬប្រពន្ធ និងឪពុកម្តាយ ឬមនុស្សចាស់៖

- ប្តីឬប្រពន្ធ=២៨%ប.ខ.
- ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុក =២៨%ប.ខ.

ឃ- ចំពោះសិទ្ធិវន្តជាប្តីឬប្រពន្ធឬកូននៅក្នុងបន្ទុក ធនលាភសម្រាប់ប្តីឬប្រពន្ធឬធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ៥៦%ប.ខ.

ង- ចំពោះសិទ្ធិវន្តជាឪពុកម្តាយឬមនុស្សចាស់ ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុក=៣៥%ប.ខ.

ច- ចំពោះសិទ្ធិវន្តជារូមមានកូននិងឪពុកម្តាយឬមនុស្សចាស់៖

- ធនលាភសរុបសម្រាប់កូន២៨%ប.ខ.
- ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុក=២៨%ប.ខ.។

**មាត្រា៩ .-**

សិទ្ធិទទួលបានធនលាភឧត្តរជីវី ត្រូវផុតរលត់ក្នុងករណីដូចខាងក្រោម៖

- នៅពេលដែលសាមីជនទទួលមរណភាព
- ប្តីឬប្រពន្ធដែលមានគូស្រករថ្មី ទោះបីជាមានឬគ្មានសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ។ ក្នុងករណីនេះ សាមីជនត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីមានគូស្រករថ្មី។

**មាត្រា១០ .-**

អាជ្ញាយុកាលនៃសិទ្ធិទាមទារវិភាជន៍បូជាសពមានរយៈពេល១(មួយ)ឆ្នាំ។

អាជ្ញាយុកាលនៃសិទ្ធិទាមទារវិភាជន៍បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង២០% និងធនលាភ មានរយៈពេល៥(ប្រាំ)ឆ្នាំ។

## ជំពូកទី៣

## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកថែទាំសុខភាព

### ផ្នែកទី១

### គោលការណ៍រួម

**មាត្រា១១ .-**

ដើម្បីទទួលបានសេវាថែទាំសុខភាព មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដូចមានចែងនៅក្នុងមាត្រា៣នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ ហើយដែលបានបង់ភាគទាន ត្រូវបង្ហាញបណ្ណសម្គាល់ខ្លួនឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដល់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម។ ចំពោះមន្ត្រីសាធារណៈដែលត្រូវបញ្ចូលក្នុងក្របខណ្ឌថ្មី ក្រសួង ស្ថាប័ន ឬអង្គភាពសាមី ត្រូវបញ្ជូនឈ្មោះមន្ត្រីសាធារណៈនោះមក**ប.ស.ស.**។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ឬអង្គភាពមានសមត្ថកិច្ច ត្រូវផ្តល់ទិន្នន័យមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលបានធ្វើបច្ចុប្បន្នកម្មរួច មកបេឡាជាតិរបបសន្តិសុខសង្គម រៀងរាល់៦(ប្រាំមួយ)ខែ ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្នែកហានិភ័យការងារនិងថែទាំសុខភាព។

គ្រប់មូលដ្ឋានសុខាភិបាលទាំងអស់ដែលបានចុះកិច្ចព្រមព្រៀងជាមួយប.ស.ស. ត្រូវផ្តល់កិច្ចសហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម ក្នុងការគ្រប់គ្រង និងផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រតាមពិធីសារឬសេចក្តីណែនាំប្រតិបត្តិគ្លីនិករបស់ក្រសួងសុខាភិបាល។

# ផ្នែកទី២
# ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

**មាត្រា១២ .-**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ រួមមាន ការផ្តល់សេវាព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ សេវាពិគ្រោះជំងឺក្រៅ សេវាសម្រាលកូន សេវាព្យាបាលថែទាំមុននិងក្រោយសម្រាល សេវាព្យាបាលដោយស្តំឬការព្យាបាលដោយចលនា និងសេវាស្តារនីតិសម្បទា និងសេវាសង្គ្រោះបន្ទាន់។

**មាត្រា១៣ .-**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវបានផ្តល់ជូនដូចខាងក្រោម៖

ក- ការផ្តល់សេវាព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ រួមមាន៖

- សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រនិងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់សម្រាកព្យាបាល (តាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋានសុខាភិបាល)។

ខ- ការផ្តល់សេវាពិគ្រោះជំងឺក្រៅ រួមមាន៖

- សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រនិងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា។

គ- ការផ្តល់សេវាសម្រាលកូន និងការព្យាបាលថែទាំមុន និងក្រោយពេលសម្រាល។

ឃ- ការផ្តល់សេវាព្យាបាលដោយស្តំ ឬការព្យាបាលដោយចលនា ឬសេវាស្តារនីតិសម្បទាដទៃទៀត។

ង- សេវាសង្គ្រោះបន្ទាន់ ក្នុងករណីសង្គ្រោះបន្ទាន់ សាមីជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាល ដែលស្ថិតនៅជិតបំផុត។ ប្រសិនបើមូលដ្ឋានសុខាភិបាលនោះមិនមានកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម សាមីជនរងគ្រោះឬអ្នកតំណាង ត្រូវជូនដំណឹងជាបន្ទាន់មកបេឡាជាតិរបបសន្តិសុខសង្គម។

**មាត្រា១៤ ._**

សេវាព្យាបាលនិងថែទាំ ដូចមានចែងក្នុងចំណុច **ក ខ គ** និង**ឃ** នៃមាត្រា១៣ខាងលើនេះ ត្រូវបានផ្តល់តែនៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គមប៉ុណ្ណោះ។ ការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលដទៃផ្សេងទៀតមិនត្រូវបានផ្តល់ជូនឡើយ លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។

## ផ្នែកទី៣

## ការផ្តល់សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ និងសេវាបញ្ជូនសព

**មាត្រា១៥ ._**

ការផ្តល់សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ ត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលតែប៉ុណ្ណោះ។

ការផ្តល់សេវាបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរមិនអាចព្យាបាលជាឬសេវាបញ្ជូនសព ត្រូវផ្តល់ជូនតាមតម្លៃរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ប.ស.ស.**។

## ផ្នែកទី៤

## ការផ្តល់សេវាបង្ការសុខភាព

**មាត្រា១៦ ._**

ការផ្តល់សេវាបង្ការសុខភាពអាចត្រូវបានផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គមកម្មវិធីជាតិបង្ការសុខភាពឬកម្មវិធីបង្ការសុខភាពដទៃផ្សេងទៀត។

សេវាបង្ការសុខភាពដែលផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ត្រូវអនុវត្តដូចគ្នានឹងកម្មវិធីបង្ការសុខភាពផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## ផ្នែកទី៥

## សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល

**មាត្រា១៧ ._**

សេវាឬការព្យាបាលដែលមិនរាប់បញ្ចូលក្នុងសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្ររួមមាន៖

- ការព្យាបាលដោយឥតបង់ថ្លៃ ដែលកំណត់នៅក្នុងគោលនយោបាយសុខាភិបាលជាតិ
- ការពិនិត្យសុខភាពទូទៅ
- ការថែទាំធ្មេញ (ការសំអាត ការប៉ះ និងការដាក់ធ្មេញ)
- សេវាប្តូរភេទ
- ការព្យាបាល ឬវះកាត់កែសម្ផស្ស ឬកែលម្អផ្នែកណាមួយនៃរាងកាយ

- សេវាបង្កកំណើតសិប្បនិម្មិត
- ការព្យាបាលអសមត្ថភាពផ្តល់កំណើត
- ការផ្សាំឬប្តូរសរីរាង្គផ្សេងៗ
- ការព្យាបាលដោយខ្លួនឯង
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត
- ការព្យាបាលញៀនសុរា ឬការព្យាបាលផ្តាច់គ្រឿងញៀន
- ការវះកាត់ដាក់គ្រាប់ភ្នែកសិប្បនិម្មិត
- ការវះកាត់បេះដូងឬសរសៃបេះដូង
- ការលាងឈាម។

សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល ដូចមានចែងក្នុងកថាខណ្ឌខាងលើ នៃមាត្រានេះ ត្រូវបានផ្តល់ជូន ក្នុងករណីត្រូវសង្គ្រោះបន្ទាន់។

សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល ដូចមានចែងក្នុងកថាខណ្ឌខាងលើ នៃមាត្រានេះ អាចពិនិត្យកែសម្រួលឡើងវិញដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ស្របតាមស្ថានភាពជាក់ស្តែង។

## ផ្នែកទី៦
## ការកំណត់ជំងឺរ៉ាំរ៉ៃ

**មាត្រា១៨ ._**

ការផ្តល់សេវាចំពោះជំងឺរ៉ាំរ៉ៃ ត្រូវធ្វើឡើងនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និងត្រូវប្រើប្រាស់តែឱសថសារវន្តដែលកំណត់ដោយក្រសួងសុខាភិបាលតែប៉ុណ្ណោះ។ ចំពោះឱសថក្រៅពីបញ្ជីឱសថសារវន្តជាបន្ទុករបស់សាមីជន។

បញ្ជីជំងឺរ៉ាំរ៉ៃ ត្រូវអនុវត្តដូចគ្នានឹងបញ្ជីជំងឺរ៉ាំរ៉ៃនៃផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

# ជំពូកទី៤
# លក្ខខណ្ឌ បែបបទ និងនីតិវិធីទូទាត់ថ្លៃសេវា និងការទាមទារតាមការលិក

## ផ្នែកទី១
## លក្ខខណ្ឌ បែបបទ និងនីតិវិធីទូទាត់ថ្លៃសេវាផ្នែកហានិភ័យការងារ

**មាត្រា១៩ ._**

ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈត្រូវបានទូទាត់សងតាមយន្តការថ្លៃតាមសេវា។

ការព្យាបាលមន្ត្រីសាធារណៈដែលរងគ្រោះដោយហានិភ័យការងារ ត្រូវតែអនុវត្តដោយមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស.**ប៉ុណ្ណោះ។

ក្នុងករណីដែលសេវានេះ ធ្វើនៅមូលដ្ឋានសុខាភិបាលដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយ**ប.ស.ស.** សាមីជនរងគ្រោះដោយហានិភ័យការងារ អាចទាមទារការទូទាត់ថ្លៃព្យាបាល និងថែទាំវេជ្ជសាស្ត្របាន។ ការទូទាត់សងថ្លៃព្យាបាលនេះត្រូវអនុលោមតាមការកំណត់របស់**ប.ស.ស.**។

ក្នុងករណីសង្គ្រោះបន្ទាន់ ជនរងគ្រោះអាចទទួលសេវាសង្គ្រោះនៅមូលដ្ឋានសុខាភិបាលណាក៏ដោយដែលជិតបំផុត។ **ប.ស.ស.** ត្រូវទូទាត់សងថ្លៃសង្គ្រោះបន្ទាន់តាមតម្លៃសមស្របជាក់ស្តែងរបស់មូលដ្ឋានសុខាភិបាល។

**មាត្រា២០ .-**

សិទ្ធិនៃការទាមទារថ្លៃតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវមានអាជ្ញាយុកាលត្រឹមរយៈពេល១២(ដប់ពីរ)ខែ គិតចាប់ពីថ្ងៃមានបញ្ហាសុខភាព។

## ផ្នែកទី២
## លក្ខខណ្ឌ បែបបទ និងនីតិវិធីទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

**មាត្រា២១ .-**

ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវធ្វើតាមយន្តការទូទាត់ថ្លៃសេវាដូចគ្នានឹងយន្តការទូទាត់ថ្លៃសេវាសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារលើកលែងតែការព្យាបាលជំងឺមហារីកដោយសារធាតុគីមី និងឱសថព្យាបាលជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម ក្រៅពីឱសថក្នុងបញ្ជីឱសថសារវន្ត ដែលត្រូវទូទាត់ថ្លៃតាមសេវាព្យាបាលនីមួយៗ។

**មាត្រា២២ .-**

សិទ្ធិនៃការទាមទារថ្លៃតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវមានអាជ្ញាយុកាលត្រឹមរយៈពេល១២(ដប់ពីរ) ខែ គិតចាប់ពីថ្ងៃមានបញ្ហាសុខភាព។

## ផ្នែកទី៣
## បែបបទនិងនីតិវិធីនៃការទាមទារតាវកាលិក

**មាត្រា២៣ .-**

បែបបទនិងនីតិវិធីនៃការទាមទារតាវកាលិកផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

# ជំពូកទី៥
# ប្រាក់ត្រៀមបម្រុង
## ផ្នែកទី១
## ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកហានិភ័យការងារ

**មាត្រា២៤ .-**

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកហានិភ័យការងារ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ប្រាក់ត្រៀមបម្រុងសម្រាប់តាវកាលិករយៈពេលវែង យ៉ាងតិចត្រូវស្មើនឹងការចំណាយ សម្រាប់ធនលាភក្នុងកំលុងពេល២(ពីរ)ឆ្នាំចុងក្រោយ។

ខ- ប្រាក់ត្រៀមបម្រុងសម្រាប់តាវកាលិករយៈពេលខ្លី យ៉ាងតិចត្រូវស្មើនឹងពាក់កណ្ដាលនៃការចំណាយលើតាវកាលិកដទៃក្រៅពីធនលាភក្នុងកំលុងពេល២(ពីរ)ឆ្នាំចុងក្រោយ។

## ផ្នែកទី២
## ប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

**មាត្រា២៥ .-**

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកថែទាំសុខភាព យ៉ាងតិចត្រូវស្មើនឹងការចំណាយលើតាវកាលិកផ្នែកថែទាំសុខភាព ក្នុងកំលុងពេល១(មួយ)ឆ្នាំចុងក្រោយ។

# ជំពូកទី៦
# យន្តការគាំទ្រ សម្របសម្រួល និងសហការ

**មាត្រា២៦ .-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចេញប្រកាសដើម្បីកំណត់នូវយន្តការគាំទ្រ សម្របសម្រួល និងសហការរវាង **ប.ស.ស.** និងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិឬអង្គភាពមានសមត្ថកិច្ច ក្នុងការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

ការផ្តល់តាវកាលិកផ្នែកហានិភ័យការងារនិងតាវកាលិកផ្នែកថែទាំសុខភាព ក្រោមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមដំណាក់កាលនិងកាលបរិច្ឆេទដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី៧
# អវសានប្បញ្ញត្តិ

**មាត្រា២៧ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៧

**ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន**

## កម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

## ផ្នែកទី១

## បញ្ជីនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ទាំងស្រុង

| ល.រ | **ការបរិយាយអំពីគ្រោះថ្នាក់** | **ភាគរយ** |
|---|---|---|
| ១ | បាត់បង់ប្រអប់ដៃទាំងពីរឬកាត់នៅផ្នែកខាងលើ | ១០០ |
| ២ | បាត់បង់ប្រអប់ដៃមួយនិងប្រអប់ជើងមួយ | ១០០ |
| ៣ | កាត់ជើងឬភ្លៅទាំងពីរឬកាត់ជើងឬភ្លៅម្ខាងនិងបាត់ប្រអប់ជើងម្ខាង | ១០០ |
| ៤ | បាត់ចក្ខុប្រសាទដែលមិនអាចបំពេញការងារដោយប្រើការមើលបាន | ១០០ |
| ៥ | ខូចទ្រង់ទ្រាយមុខធ្ងន់ធ្ងរ | ១០០ |
| ៦ | ថ្លង់ទាំងស្រុង | ១០០ |

## ផ្នែកទី២

## បញ្ជីនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដោយផ្នែក

| ល.រ | **ការបរិយាយអំពីគ្រោះថ្នាក់** | **ភាគរយ** |
|---|---|---|
| **ក- ការកាត់អវៈយវៈខាងលើ (ដៃណាក៏ដោយ)** | | |
| ១ | កាត់សន្លាក់ស្មា | ៩០ |
| ២ | កាត់ក្រោមស្មាដែលគល់នៅតិចជាង ៨" ពីចុងនៃ acromion | ៨០ |
| ៣ | កាត់ ៨" ពីចុងនៃ acromion ទៅតិចជាង ៩" ក្រោមចុងនៃ olecranon | ៧០ |
| ៤ | បាត់ប្រអប់ដៃឬមេដៃនិងម្រាម៤នៃប្រអប់ដៃមួយ ឬកាត់ ៤,៥" ខាងក្រោមចុងនៃ olecranon | ៦០ |
| ៥ | បាត់មេដៃមួយ | ៣០ |
| ៦ | បាត់មេដៃមួយនិងឆ្អឹង metacarpal | ៤០ |
| ៧ | បាត់ម្រាមបួននៃប្រអប់ដៃម្ខាង | ៥០ |
| ៨ | បាត់ម្រាមបីនៃប្រអប់ដៃម្ខាង | ៣០ |
| ៩ | បាត់ម្រាមពីរនៃប្រអប់ដៃម្ខាង | ២០ |
| ១០ | បាត់ថ្នាំងចុងក្រោយនៃមេដៃ | ២០ |
| **ខ- ការកាត់អវៈយវៈខាងក្រោម** | | |
| ១១ | កាត់ប្រអប់ជើងទាំងពីរបណ្តាលឲ្យដើរខ្វិច | ៩០ |
| ១២ | កាត់តាម feet proximal ទាំងពីរទៅ metatarso-phalangeal joint | ៨០ |
| ១៣ | បាត់ម្រាមជើងទាំងអស់នៃប្រអប់ជើងទាំងពីរតាម metatarso-phalangeal joint | ៤០ |
| ១៤ | បាត់ម្រាមជើងទាំងអស់នៃ feet proximal ទាំងពីរទៅ proximal inter-phalangeal joint | ៣០ |

| | | |
|---|---|---|
| ១៥ | បាត់ម្រាមជើងទាំងអស់នៃ feet distal ទាំងពីរទៅ proximal inter-phalangeal joint | ២០ |
| ១៦ | កាត់ត្រគាក | ៩០ |
| ១៧ | កាត់ក្រោមត្រគាកសល់គល់មិនលើស ៥" ដោយវាស់ពីចុងនៃ great trenchanter | ៨០ |
| ១៨ | កាត់ក្រោមត្រគាកសល់គល់មិនលើស ៥" ដោយវាស់ពីចុងនៃ great trenchanter ប៉ុន្តែមិនហួសពីពាក់កណ្តាលភ្លៅ | ៧០ |
| ១៩ | កាត់ក្រោមពាក់កណ្តាលភ្លៅទៅ ៣,៥" ក្រោមជង្គង់ | ៦០ |
| ២០ | កាត់ក្រោមជង្គង់ដោយនៅសល់គល់លើសពី ៣,៥" ប៉ុន្តែមិនហួសពី ៥" | ៥០ |
| ២១ | កាត់ក្រោមជង្គង់ដោយនៅសល់គល់លើសពី ៥" | ៤០ |
| ២២ | កាត់ប្រអប់ជើងមួយបណ្តាលឲ្យដើរទប់ខាងចុង | ៣០ |
| ២៣ | កាត់ពី foot proximal មួយទៅ metatarso-phalangeal joint | ៣០ |
| ២៤ | បាត់ម្រាមជើងទាំងអស់នៃប្រអប់ជើងម្ខាងតាម metatarso-phalangeal joint | ២០ |
| **គ- ភ្នែក ត្រចៀក** | | |
| ២៥ | បាត់ភ្នែកម្ខាង ដោយមិនមាន Complications ហើយភ្នែកម្ខាងទៀតនៅធម្មតា | ៤០ |
| ២៦ | បាត់បង់គំហើញភ្នែកម្ខាងដោយមិនមាន Complications ឬដោយគ្មានខូចទ្រង់ទ្រាយ គ្រាប់មួយទៀតនៅធម្មតា | ៣០ |
| ២៧ | ត្រចៀកម្ខាងថ្លង់ទាំងស្រុង | ២០ |
| **ឃ- ម្រាមដៃឆ្វេងឬស្តាំ** | | |
| ចង្អុលដៃ | | |
| ២៨ | ទាំងមូល | ១៤ |
| ២៩ | ពីរថ្នាំង | ១១ |
| ៣០ | មួយថ្នាំង | ៩ |
| ៣១ | កាត់ចុងម្រាមដោយម៉ាស៊ីន តែមិនបាត់ឆ្អឹង | ៥ |
| ម្រាមកណ្តាល | | |
| ៣២ | ទាំងមូល | ១២ |
| ៣៣ | ពីរថ្នាំង | ៩ |
| ៣៤ | មួយថ្នាំង | ៧ |
| ៣៥ | កាត់ចុងម្រាមដោយម៉ាស៊ីន តែមិនបាត់ឆ្អឹង | ៤ |
| នាងដៃនិងកូនដៃ | | |
| ៣៦ | ទាំងមូល | ៧ |
| ៣៧ | ពីរថ្នាំង | ៦ |
| ៣៨ | មួយថ្នាំង | ៥ |
| ៣៩ | កាត់ចុងម្រាមដោយម៉ាស៊ីន តែមិនបាត់ឆ្អឹង | ២ |
| **ង-ម្រាមជើងឆ្វេងឬស្តាំ** | | |
| មេជើង | | |
| ៤០ | Through metatarso-phalangeal joint | ១៤ |

| | | |
|---|---|---|
| ៤១ | Part, with some loss of bone | ៣ |
| ម្រាមជើងដទៃទៀត | | |
| ៤២ | Through metatarso-phalangeal joint | ៣ |
| ៤៣ | Part, with some loss of bone | ១ |
| ម្រាមពីរនៃប្រអប់ជើងណាមួយ ដោយមិនគិតមេជើង | | |
| ៤៤ | Through metatarso-phalangeal joint | ៥ |
| ៤៥ | Part, with some loss of bone | ២ |
| ម្រាមបីនៃប្រអប់ជើងណាមួយ ដោយមិនគិតមេជើង | | |
| ៤៦ | Through metatarso-phalangeal joint | ៦ |
| ៤៧ | Part, with some loss of bone | ៣ |
| ម្រាមបួននៃប្រអប់ជើងណាមួយ ដោយមិនគិតមេជើង | | |
| ៤៨ | Through metatarso-phalangeal joint | ៩ |
| ៤៩ | Part, with some loss of bone | ៣ |

បញ្ជីនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍អាចកែសម្រួលបានដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សម្គាល់ :

- ការបាត់បង់សមត្ថភាពប្រើប្រាស់ទាំងស្រុងនិងអចិន្ត្រៃយ៍នៃអវយវៈ ឬសរីរាង្គណាមួយ ដូចមានចែងក្នុងតារាងខាង លើត្រូវចាត់ទុកដូចជាការបង់អវយវៈ ឬសរីរាង្គនោះ
- សញ្ញា « " » ហៅថាអ៊ិញ (inch) ដែល 1inch ≃ ២,៥៤ cm

ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៧
**ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន**

## តារាងមេគុណតម្លៃបច្ចុប្បន្ន

| អាយុ | មេគុណ |
|---|---|
| ០ | ១៣ ៧៧៣ |
| ១ | ១៣ ៨២៣ |
| ២ | ១៣ ៧៣៧ |
| ៣ | ១៣ ៦៤៨ |
| ៤ | ១៣ ៥៥៩ |
| ៥ | ១៣ ៤៦៩ |
| ៦ | ១៣ ៣៧៩ |
| ៧ | ១៣ ២៨៨ |
| ៨ | ១៣ ១៩៦ |
| ៩ | ១៣ ១០២ |
| ១០ | ១៣ ០០៧ |
| ១១ | ១២ ៩០៩ |
| ១២ | ១២ ៨០៩ |
| ១៣ | ១២ ៧០៥ |
| ១៤ | ១២ ៥៩៨ |
| ១៥ | ១២ ៤៨៨ |
| ១៦ | ១២ ៣៧៥ |
| ១៧ | ១២ ២៥៩ |
| ១៨ | ១២ ១៤៤ |
| ១៩ | ១២ ០២៦ |
| ២០ | ១១ ៩០៥ |
| ២១ | ១១ ៧៨២ |
| ២២ | ១១ ៦៥៨ |
| ២៣ | ១១ ៥៣១ |
| ២៤ | ១១ ៤០២ |
| ២៥ | ១១ ២៧២ |

| | |
|---|---|
| ២៦ | ១១ ១៨០ |
| ២៧ | ១១ ០០៥ |
| ២៨ | ១០ ៨៦៩ |
| ២៩ | ១០ ៧៣០ |
| ៣០ | ១០ ៥៩០ |
| ៣១ | ១០ ៤៤៨ |
| ៣២ | ១០ ៣០៣ |
| ៣៣ | ១០ ១៥៦ |
| ៣៤ | ១០ ០០៧ |
| ៣៥ | ៩ ៨៥៧ |
| ៣៦ | ៩ ៧០៤ |
| ៣៧ | ៩ ៥៤៩ |
| ៣៨ | ៩ ៣៩២ |
| ៣៩ | ៩ ២៣២ |
| ៤០ | ៩ ០៧១ |
| ៤១ | ៨ ៩០៧ |
| ៤២ | ៨ ៧៤១ |
| ៤៣ | ៨ ៥៧៣ |
| ៤៤ | ៨ ៤០២ |
| ៤៥ | ៨ ២២៩ |
| ៤៦ | ៨ ០៥៣ |
| ៤៧ | ៧ ៨៧៥ |
| ៤៨ | ៧ ៦៩៤ |
| ៤៩ | ៧ ៥១២ |
| ៥០ | ៧ ៣២៩ |
| ៥១ | ៧ ១៤២ |
| ៥២ | ៦ ៩៥៣ |
| ៥៣ | ៦ ៧៦០ |
| ៥៤ | ៦ ៥៦៤ |
| ៥៥ | ៦ ៣៦៦ |
| ៥៦ | ៦ ១៦៧ |
| ៥៧ | ៥ ៩៦៧ |
| ៥៨ | ៥ ៧៦៧ |

| | |
|---|---|
| ៥៩ | ៥ ៥៦៨ |
| ៦០ | ៥ ៣៧១ |
| ៦១ | ៥ ១៧៦ |
| ៦២ | ៤ ៩៨៨ |
| ៦៣ | ៤ ៧៩៣ |
| ៦៤ | ៤ ៦០៥ |
| ៦៥ | ៤ ៤១៩ |
| ៦៦ | ៤ ២៣៨ |
| ៦៧ | ៤ ០៥១ |
| ៦៨ | ៣ ៨៦៩ |
| ៦៩ | ៣ ៦៨៩ |
| ៧០ | ៣ ៥១១ |
| ៧១ | ៣ ៣៣៥ |
| ៧២ | ៣ ១៦២ |
| ៧៣ | ២ ៩៩៥ |
| ៧៤ | ២ ៨៣៧ |
| ៧៥ | ២ ៦៨៧ |
| ៧៦ | ២ ៥៤១ |
| ៧៧ | ២ ៣៩៩ |
| ៧៨ | ២ ២៥៩ |
| ៧៩ | ២ ១២២ |
| ៨០ | ១ ៩៨៨ |
| ៨១ | ១ ៨៥៦ |
| ៨២ | ១ ៧២៨ |
| ៨៣ | ១ ៦០៥ |
| ៨៤ | ១ ៤៨៦ |
| ៨៥ | ១ ៣៧២ |
| ៨៦ | ១ ២៦៣ |
| ៨៧ | ១ ១៦០ |
| ៨៨ | ១ ០៦៣ |
| ៨៩ | ៩៧១ |
| ៩០ | ៨៨៥ |
| ៩១ | ៨០៤ |

| | |
|---|---|
| ៩២ | ៧២៧ |
| ៩៣ | ៦៥៥ |
| ៩៤ | ៥៨៧ |
| ៩៥ | ៥២២ |
| ៩៦ | ៤៥៩ |
| ៩៧ | ៣៩៣ |
| ៩៨ | ៣១៤ |
| ៩៩ | ២៤៣ |
| ១០០ | ១៨២ |